# ការសំភាសន៍របស់អ្នកមីង ចាន់ ឡូត

ក៖ អ្នកដែរសំភាសន៍គេមាន ជាង ស៊ីអ៊ាវ ខ៖ អ្នកដែរអោយគេសំភាសន៍ ចាន់ ឡូត

## <u>ការសង្ខេបប្រវត្តិរបស់ អ្នកមីង ចាន់ ឡូត</u>

អ្នកមីង ចាន់ ឡូត មានអាយុ37ឆ្នាំ នៅក្នុងឆ្នាំ2018 អ្នកមីង ចាន់ ឡូត មានភេទស្រី អ្នកមីង ចាន់ ឡូត មានទីលំនៅបច្ចុប្បន្ននៅ ភូមិស្ពានបាក់ ឃុំព្រែកកំពិស ខ័ណ្ឌដង្កោ រាជធានីភ្នំពេញ។

ក៖ ចឹងជាដំបូងខ្ញុំអរគុណច្រើនមីងដែរបានអោយខ្ញុំពិភាក្សាជាមួយយាយដែរទាក់ទងពីប្រវត្តិរបស់យាយ ហើយការសំភាសន៍ទាំងអស់នេះត្រូវបានរៀបចំដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថាBYU ហើយដោយសារតែសកលវិទ្យាមានគោលបំណងចង់រក្សាពីប្រវត្តិរបស់ប្រជាជនខ្មែរ ដើម្បីទុកអោយកូនចៅជំនាន់ក្រោយៗអោយពួកគាត់ បានស្គាល់នឹងបានដឹងពីប្រវត្តិរបស់ឪពុកម្ដាយនឹង ប្រវត្តិរបស់ដូនតាចឹងនៅពេលដែរខ្ញុំបានសំភាសន៍មីង ហើយនឹងខ្ញុំនឹងដាក់ការសំភាសន៍ទាំងអស់នឹងទៅក្នុងវេបសាយរបស់សាលាដែរមានឈ្មោះថា www.cambodianoralhistories.byu.edu ចឹងសំរាប់មីងយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍ទាំងអស់នឹងទៅក្នុងវេបសាយរបស់សាលាដែរទេមីង?

ខ៖ ចាំ!!

ក៖ បាទចឹងសំរាប់ខ្ញុំជាអ្នកសំភាសន៍មីងខ្ញុំមានឈ្មោះថា ជាង ស៊ីអ៊ាវ ហើយថ្ងៃខែដែរខ្ញុំបានសំភាសន៍មីងគឺនៅថ្ងៃទី19ខែ4 ឆ្នាំ2018 ហើយការងារទាំងអស់នេះគឺធ្វើឡើងនៅភូមិភូមិនឹងភូមិអីគេមីង?

ខ៖ ភូមិស្ពានបាក់

ក៖ ភូមិមានបាក់?

ខ៖ ភូមិស្ពានបាក់

ក៖ ភូមិស្ពានបាក់ណាមីងណា?

ខ៖ ចាំ!!

ក៖ ចុះឃុំអីគេដែរមីង?

ខ៖ ឃុំព្រែកកំពិស

ក៖ ឃុំព្រែកកំពិស ខ័ណ្ឌដង្កោ?

ខ៖ រាជធានី

ក៖ រាជធានីភ្នំពេញណាមីង?

ខ៖ ចាំ!!

ក៖ ចុះមីងសំរាប់មីងឈ្មោះពេញរបស់មីងនឹងមានឈ្មោះអីគេដែរមីង?

ខ៖ ខ្ញុំមានឈ្មោះចាន់

ក៖ មានឈ្មោះហៅក្រៅទេមីង?

ខ៖ អត់

ក៖ ចុះកាលពីក្មេងនឹងធ្លាប់មាននរណាហៅឈ្មោះមីងអីផ្សេងដែរទៅមីង?

ខ៖ អត់មានទេ

ក៖ ឈ្មោះចាន់នឹងអីគេ ចាន់ដែរមីង?

ខ៖ ឈ្មោះឡូត ចាន់

ក៖ ឈ្មោះឡូត ចាន់ណាមីង?

ខ៖ ចាំ!!

ក៖ ចុះឆ្នាំនឹងមីងអាយុប៉ុន្មានដែរមីង?

ខ៖ ខ្ញុំអាយុ37ឆ្នាំ

កះ មីងអាយុ37ឆ្នាំ ចុះមីងកើតនៅថ្ងៃខែឆ្នាំណាមីងមានចាំទេមីង?

ខះ អត់ចាំទេខ្ញុំនោះ

កះ ថ្ងៃខែក៏អត់ចាំដែរណាមីង?

ខះ ទាល់តែមើល

កះ ចឹងមីងកើតនៅឆ្នាំ1981មែនទេមីង ខ្ញុំគួរតែហៅបងស្រីទើបតែអាយុ37ឆ្នាំ ចុះសំរាប់ឆ្នាំច័ន្ទគតិបងស្រីឆ្នាំអីគេដែរបង លក្ខណះឆ្នាំជូត ឆ្លូវ ខាល ថោះបង?

ខះ ឆ្នាំរកា

កះ ឆ្នាំរកាណោះបង?

ខះ ចា៎!!

កះ ចុះបងកើតនៅភូមិអី ឃុំអី ស្រុកអីដែរទៅបង?

ខះ ខ្ញុំកើតនៅភូមិព្រៃកកំពិស ស្រីស្នមយើងនឹងស្ពានបាក់យើងនឹង

កះ អូ៎!!

ខះ ខ្ញុំកើតនៅនឹងតែម្តង

កះ ចឹងកើតនៅនឹងតែម្តងហោសបង?

ខះ ចា៎!!

កះ ចុះសំរាប់ដូចជាបងមានបងប្អូនចំនួនប៉ុន្មាននាក់ដែរបង?

ខះ បងប្អូនច្រើនណាស់7នាក់ហោស

កះ មាន7នាក់ហោស ចុះបងជាកូនទីប៉ុន្មានដែរទៅ?

ខះ ខ្ញុំបងគេ

កះ ចុះមានស្រីប៉ុន្មានប្រុសប៉ុន្មានដែរបង?

ខះ មានស្រី3អូស្រី4នាក់ទាំងខ្ញុំ

កៈ ចុះប្រុស3នាក់?

ខៈ ប្រុសមាន3នាក់

កៈ ចុះបងមានចងចាំឈ្មោះបងប្អូនរបស់បងទេ
បងប្អូនរបស់បងមានឈ្មោះអីគេខ្លះដែរទៅ?

ខៈ នៅឆ្ងាយៗៗណាស់

កៈ ប៉ុន្តែឈ្មោះពួកគាត់ហាសបងមានចងចាំទេ ដូចជាពួកគាត់មានឈ្មោះអីចឹងហាស?

ខៈ បងប្អូនរបស់ខ្ញុំនឹង

កៈ បាទ!!បង?

ខៈ ឈ្មោះអ៊ុយ

កៈ នឹងប្អូនទី2ណោះបង?

ខៈ នឹងបន្ទាប់ខ្ញុំ

កៈ ចុះទី3បង?

ខៈ ឈ្មោះជាតិ

កៈ ចុះទី4វិញបង?

ខៈ ទី4ឈ្មោះឡា

កៈ ចុះទី5ហាសបង?

ខៈ ទី5ឈ្មោះអានី

កៈ ចុះទី6វិញបង?

ខៈ ឈ្មោះញៀន

កៈ ចុះទី7វិញ?

ខៈ ឈ្មោះញ៉ាញ

កៈ ចុះសំរាប់បងមានអនុស្សាវរីយ៍អីកាលនៅក្មេងៗជាមួយគ្នាហាសបង ដូចលក្ខណៈថាលេង ឡឹកបាយឡ លេងអីចឹងបងធ្លាប់មានអនុស្សាវរីយ៍អីជាមួយពួកគាត់ដែរទេ?

ខៈ ខ្ញុំអត់ដែរលេងផងខ្ញុំធំជាងគេ

កៈ ប៉ុន្តែប្អូនៗរបស់បងនឹងគាត់ធ្លាប់លេង?

ខៈ ធ្លាប់លេង

កៈ ប៉ុន្តែបងធំជាងគេបងអត់លេងទេ?

ខៈ ខ្ញុំអត់លេងទេខ្ញុំដឹងតែរៀននឹងអត់បានរៀនផងនឹង

កៈ អូ៎!!

ខៈ យើងរវល់មើលប្អូនផង ឃ្វាលគោផង យើងឆ្លៀតទៅរៀនផងហើយរៀនអត់បានប៉ុន្មានម៉ែឪរបស់ខ្ញុំវា អត់គ្មានបានរៀនណាខ្ញុំអត់ចេះអក្សរផងនឹង

កៈ ចឹងបងអត់បានចូលរៀនទេណា?

ខៈ អត់ចូលរៀនដែរប៉ុន្តែគ្រាន់តែមើលទៅវាពិបាកពេកក៏ខ្ញុំឈប់ទៅ

កៈ ចុះកាលពីរៀននឹងរៀននៅណាទៅបង?

ខៈ រៀននឹងនៅព្រែកកំពិសនេះ

កៈ ចុះបងមានចាំឈ្មោះសាលាទេមានឈ្មោះអីទៅសាលាដែរបងរៀននឹងហាស?

ខៈ មិនដឹងឈ្មោះសាលាអីទេព្រែកកំពិស ព្រែកថ្លឹងនឹង

កៈ បាទ!!បងបាទ?

ខៈ ខ្ញុំហៅតែព្រែកថ្លឹងនឹង

កៈ បាទ!!ភាគច្រើនបងប្អូនរបស់បងចូលចិត្តលេងអីជាមួយគ្នាដែរបង?

ខៈ ខ្ញុំកំរលេង កំរលេងឡឹកបាយឡផងអត់ចេះលេង

កះ អត់ចេះលេង?

ខះ គិតទៅគ្រាន់តែថាធំពេញវ័យដឹងតែបាយទឹកហើយ
ចុះម៉ែឪគាត់អត់ពិបាកបាយទឹករែកទឹកអោយប្អូន គក់ខោអាវប្អូន ដាំបាយអោយប្អូនហាស

កះ បាទ!!បាទបង?

ខះ ច្រូតស្មៅ ព្រឹកព្រលឹមឡើងដឹងតែច្រូតស្មៅគោច្រូតអីនឹងហាសពីមុនហាស

កះ បាទ!!បងបាទ?

ខះ តែអីខ្ញុំអត់ចេះលេងផង

កះ ប៉ុន្តែប្អូនរបស់បងនឹងគាត់មានគ្រួសារទាំងអស់គ្នានៅបង?

ខះ មានអស់ហើយនឹង

កះ ទាំងអស់គ្នាតែម្តងហោសបង?

ខះ ចាំ!!

កះ ប៉ុន្តែដូចជាសព្វថ្ងៃពួកគាត់រស់នៅណាខ្លះដែរទៅ?

ខះ គាត់នៅណែគាត់ទៅនៅណោះពីរនាក់នៅព្រៃវែងមួយ នៅឆ្នាពូនមួយ

កះ អូ៎!!

ខះ នៅនឹងទាំងអស់នឹងខ្ញុំនៅមើលក្មួយៗហើយអត់មានម្តាយផងនឹង

កះ អូ៎!!បាទបងបាទ?

ខះ ហើយពុកខ្ញុំពិការនឹងនៅផ្ទះ

កះ ហើយចុះ?

ខះ នៅកាន់ឈើច្រត់នឹង

កះ ចុះសំរាប់ប្អូនៗរបស់បងនៅព្រៃវែងនឹងគាត់ធ្វើអីគេដែរទៅបង?

ខះ គាត់ធ្វើស្រែធ្វើអីគាត់នឹង

កៈ ចុះនៅណានៅនឹងគាត់ធ្វើអីគេដែរទៅបង?

ខៈ គាត់ធ្វើស្រែគាត់ធ្វើសំណង់ធម្មតានឹង

កៈ អ្នកនៅនឹងគាត់ធ្វើស្រែ នឹងធ្វើសំណង់ហោសមីង?

ខៈ ខ្ញុំនៅនេះខ្ញុំមានស្រែ ប្អូនគេនៅនោះគេមានខាងប្រពន្ធហាស

កៈ បាទ!!បងបាទ?

ខៈ ខ្ញុំនៅនេះខ្ញុំអត់មានទេខ្ញុំទិញតែអង្ករគីឡូនឹង

កៈ អូ៎!!បាទបង?

ខៈ ចា៎!!ហើយខ្ញុំមើលក្មួយៗនៅនេះអត់មានមនុស្សមើលផងនឹង ហើយខ្ញុំចិញ្ចឹមបងប្អូននឹង

កៈ ចឹងហោសបងហោស?

ខៈ ចា៎!!ចិញ្ចឹមបងប្អូនចិញ្ចឹមពួកគាត់នឹង

កៈ អូ៎!!ចុះសំរាប់ឪពុករបស់បងនឹងមានឈ្មោះអីគេដែរបង?

ខៈ ឈ្មោះឡូត ដៅឡូត

កៈ ចុះគាត់ឥឡូវនឹងគាត់អាយុប៉ុន្មានដែរទៅ?

ខៈ គាត់អាយុហាជាងហើយប៉ុន្តែគ្រាន់តែគាត់ស្ងិតជើងហាស

កៈ អូ៎!!បាទគាត់នៅលើមែន?

ខៈ គាត់នៅក្រោមហោសគាត់កាន់ឈើច្រត់នឹង

កៈ អូ៎!!បាទ ចុះឪពុករបស់បងនឹងគាត់កើតនៅណាបងមានដឹងទេ?

ខៈ ខ្ញុំអត់ដឹងផង

កៈ អូ៎!!ចុះម្តាយរបស់បងគាត់មានឈ្មោះអីទៅ?

ខៈ ម្តាយរបស់ខ្ញុំនឹងគាត់ស្លាប់បាត់ហើយ

កៈ ប៉ុន្តែគាត់មានឈ្មោះអីគេដែរទៅ?

ខៈ ឈ្មោះមីង ញ៉ឹង

កៈ អូ៎!!ឈ្មោះមីង ញ៉ឹង?

ខៈ ចា៎!!

កៈ ចុះគាត់កើតនៅណាដែរបងចាំទេ?

ខៈ ខ្ញុំអត់ចាំគាត់អត់ប្រាប់ផង

កៈ ចុះកាលពីឪពុករបស់បងកាលនៅក្មេងៗគាត់ធ្វើអីគេសំរាប់ចិញ្ចឹមជីវិត នឹងចិញ្ចឹមក្រុមគ្រួសារហាស?

ខៈ កាលពីគាត់នៅពីមុនហោស

កៈ បាទ!!បងបាទ?

ខៈ គាត់អើរនេះគាត់ដើររកត្រី បង់ត្រីទេ គាត់ដើរធ្វើផ្ទះអោយគេផ្ទះឈើអីចឹងហាសណាស់

កៈ បាទ!!បងបាទ?

ខៈ គេរកគាត់អោយធ្វើចឹងទៅ

កៈ អូ៎!!ចឹងមានន័យថាឪពុករបស់បងគាត់ចេះធ្វើផ្ទះ?

ខៈ ចា៎!!ឥឡូវនឹងគាត់ធ្វើអត់កើតផង

កៈ អូ៎!!បាទចុះគាត់កាចរឺមួយក៏ស្លូតដែរបង?

ខៈ គាត់អត់កាចទេ

កៈ គាត់ស្លូតដែរណបង?

ខៈ ចា៎!!

កៈ ចុះម្តាយរបស់បងគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរបង?

ខៈ ម្តាយរបស់ខ្ញុំស្លាប់យូរហើយ

កៈ ប៉ុន្តែពីមុនគាត់នៅរស់ហាស គាត់ធ្វើអីគេទៅ?

ខៈ ពីមុនអត់អត់មានធ្វើអីផង តែគាត់ពីមុនប្ដីរបស់គាត់ផឹកដែរគាត់ពិបាកគាត់

កៈ អូ៎!!

ខៈ កាលពីមុនខ្ញុំវេទនាខ្ញុំអត់ផងនឹង

កៈ បាទ!!បងបាទ?

ខៈ ដើរស៊ីឈ្នួលគេស្ទូងអីនឹងហាស

កៈ អូ៎!!រហូតដល់ឥឡូវនឹងវារៀងធូរជាងមុនណាបង?

ខៈ ចាំ!!វារៀងធូរគ្រាន់តែថាវាបានកូន

កៈ បាទ!!បង?

ខៈ កូននឹងប្ដីប្រឹងធ្វើការទៅ
ហើយពេលដែរយើងជំពាក់គេអីយើងអត់មានដីស្រែដូចគេហាស

កៈ បាទ!!បងបាទ?

ខៈ យើងអត់តែម្ដងតស៊ូពីអត់តែម្ដង

កៈ ចុះម្ដាយរបស់បងគាត់កាចរឺមួយក៏ស្លូតដែរបង?

ខៈ គាត់កាចដែរម្ដាយរបស់ខ្ញុំនឹង

កៈ អូ៎!!ចុះបងមានចងចាំអនុស្សាវរីយ៍អីកាលពីបងនៅជាមួយឪពុកម្ដាយរបស់បងទេបង
ថាធ្លាប់លេងអីជាមួយគ្នាធ្លាប់បានធ្វើអីជាមួយគ្នាចឹងហាសបង?

ខៈ ធ្វើជាមួយម្ដាយនឹងមានធ្វើអីមានតែដើរស៊ីឈ្នួលស្ទូងអោយគេ

កៈ អូ៎!!

ខៈ ចាំ!!យកលុយមកទិញអង្ករហូបចឹងទៅ

កៈ បាទ!!បង?

ខ៖ គេស្តីអោយពីមុខពីក្រោយ

ក៖
ចុះសំរាប់ឪពុករបស់បងគាត់មានធ្លាប់ប្រាប់ពីប្រវត្តិរបស់គាត់កាលពីនៅក្មេងទៅបងដែរទេ
?

ខ៖ អត់ផង

ក៖ អត់ដែរទេណា?

ខ៖ ចាំ!!

ក៖ ចុះម្តាយរបស់បងវិញគាត់មានធ្លាប់ប្រាប់ពីប្រវត្តិរបស់គាត់ទៅបងទេ?

ខ៖ គាត់មិនដែរប្រាប់ផផង

ក៖ ចុះយាយតាខាងឪពុកបងមានស្គាល់ឈ្មោះគាត់ដែរទេបង?

ខ៖ អត់ស្គាល់ទេបងគាត់ស្លាប់យូរហើយ

ក៖ ចុះគាត់កើតនៅណាក៏បងអត់ដឹងដែរណាបង?

ខ៖ អត់ខ្ញុំនិយាយរួមនឹងខ្ញុំទើបតែកើតដែរគាត់ស្លាបតាំងពីមុនខ្ញុំកើតទៀតណោះនឹង

ក៖ អូ៎!!

ខ៖ តាំងពីមុនខ្ញុំកើតមកហើយនឹងចា

ក៖ ចុះយាយតាខាងម្តាយវិញ?

ខ៖ នឹង

ក៖ ក៏បងអត់ដឹងដែរ?

ខ៖ ចាំ!!ខ្ញុំស្គាល់តែខាងគាត់នឹង

ក៖ អូ៎!!

ខ៖ ខាងឪពុកនឹង

កះ ចុះសំរាប់ដូចជាបងមករស់នៅនឹងយូរនៅបង?

ខះ ខ្ញុំរស់នៅនឹងយូរហើយតើអូន

កះ នៅតាំងពីកើតហោសបង?

ខះ ចា៎!!

កះ អូ៎!!បាទ ចុះបងមានបងប្អូនរឺមួយក៏សាច់ញ្ញាតិណាដែរទៅរស់នៅក្រៅប្រទេសទេបង?

ខះ អត់មានផង

កះ បងប្អូនជីដូនមួយអីក៏អត់មានដែរណាបង?

ខះ អត់

កះ ចុះសំរាប់ស្វាមីរបស់បងនឹងគាត់ានឈ្មោះអីគេដែរទៅបង?

ខះ ប្តីរបស់ខ្ញុំហោស?

កះ បាទ!!បង?

ខះ ឈ្មោះទន ទុំ

កះ ចុះបងមានចាំថាបងរៀបអាពាហ៍ពិពាហ៍នៅថ្ងៃខែឆ្នាំណាបងមានចងចាំទេ?

ខះ នៅឆ្នាំកៅជាង

កះ នៅឆ្នាំកៅជាងហោសបង ចុះសំរាប់?

ខះ កៅជាងអីទេប៉ែតជាងទេអូ1986ទេមិនដឹង

កះ មិនមែនបៃតទេបងដោយសារតែបងទើបតែកើតនៅឆ្នាំ1981ទេនឹងបង

ខះ កៅជាងនឹង

កះ អូ៎!!កាលបងការនឹងអាយុប៉ុន្មានដែរទៅ?

ខះ ការក្មេងដែរខ្ញុំអាយុ15-16ឆ្នាំនឹង

កះ អូ៎!!ចឹងកៅជាងណាបង?

ខ៖ ចាំ!!គ្រាន់តែថាការឥឡូវនឹងចាអាយុ20ជាងឆ្នាំហើយ

ក៖ បាទ!!បង
ចុះសំរាប់បងគិតថាដូចជានៅពេលដែរបងរៀបអាពាហ៍ពិពាហ៍ជាមួយប្ដីរបស់បង
ដូចជាបងជាអ្នករៀបចំរៀបដោយខ្លួនឯងរឺក៏ឪពុកម្ដាយជាអ្នករៀបចំអោយដែរបង?

ខ៖ ឪពុកម្ដាយ

ក៖ ប៉ុន្ដែពេលណុងមានជាជំនួនអត់បង?

ខ៖ មានដែរតើ!!

ក៖ ដូចជាមានជាប៉ុន្មានដែរបងពេលណុង ដូចជាគេចូលស្ដីបងគេជូនអីទៅបងពេលណុង?

ខ៖
អត់មានអីទេគ្រាន់តែថាចាស់ៗគេមកចូលស្ដីចឹងទៅណាស់មាននុំមាននែកមានអីគ្រប់ស
ព្វចឹងទៅ ណាស់

ក៖ អូ៎!!បាទបង?

ខ៖ ចាំៗៗ!!

ក៖ ចុះបងគិតថាសំរាប់ដូចជានៅពេលដែរបងរៀបអាពាហ៍ពិពាហ៍
បងអាចប្រាប់ពីពេលដំបូងដែរបង
បានស្គាល់ប្ដីបងនៅពេលណាហើយហេតុអីបានជាស្គាល់គ្នា?

ខ៖ ខ្ញុំអត់ស្គាល់ផងនិយាយរួមចាស់ៗគាត់ស្ដីគាត់ស្រលាញ់គាត់ស្ដី
ខ្ញុំអត់ដែរស្គាល់ប្ដីរបស់ខ្ញុំទេ

ក៖ អូ៎!!ចឹងហោស?

ខ៖ ទាល់តែពេលនេះបានខ្ញុំស្គាល់

ក៖ អូ៎!!បាទបងបាទ?

ខ៖ ទាល់តែជិតការបានខ្ញុំស្គាល់ប្ដី

ក៖ បាទ!!ចុះបងគិតថាបងមានចេះភាសាអីក្រៅពីភាសាខ្មែរទេបង?

ខ៖ អត់

ក៖ ចឹងបងចេះតែខ្មែរទេណាបង?

ខ៖ ចាំៗៗ!!

ក៖
ចុះបងគិតថាសំរាប់ការពីបងនៅរៀនបងធ្លាប់មានមិត្តភក្តិដែរស្និទ្ធិស្នាលធំធាត់មកជាមួយគ្នាទេ?

ខ៖ ខ្ញុំអត់ដែរមានមិត្តភក្តិផង

ក៖ អូ៎!!ដូចជាបងប្អូនអីបានមាន?

ខ៖ ចាំ!!អត់មានមិត្តភក្តិសោះ

ក៖ ប៉ុន្តែបងដូចជាធ្លាប់លេងអីជាមួយបងប្អូនជីដូនមួយ
រឺមួយក៏លេងអីជាមួយគ្នាការនៅក្មេងៗៗទេ?

ខ៖ ខ្ញុំលេងមានតែឃ្វាលគោខ្ញុំលេងហោសចឹងហាសណាស់

ក៖ អូ៎!!ធ្លាប់ឃ្វាលគោណបង?

ខ៖ នឹងហើយឃ្វាលគោខ្ញុំលេង
ខ្ញុំលេងដូចថាខ្ញុំលេងលេងលោតលើដើមឈើលោតទំលាក់ខ្លួនអីចឹង
ហាសណាស់មានតែប៉ុណ្ណឹងចាំ

ក៖ លេងលោត លោតយ៉ាងម៉េចទៅបង?

ខ៖ ដើមឈើចឹងយើងលោតមកតាមដើមឈើចឹងទៅ

ក៖ អត់អីទេណា?

ខ៖ នឹងកាលពីមុនអត់អីទេដើមរាំងវាទោលៗៗចេះដែរនឹង

ក៖ អូ៎!!បាទ?

ខ៖ ចាំ!!

កៈ ចុះសំរាប់បងធ្លាប់ធ្វើស្រែចំការដែរណាបងណា?

ខៈ ខ្ញុំពីមុននឹងខ្ញុំធ្លាប់ធ្វើ

កៈ ប៉ុន្តែបងធ្វើអីគេដែរនៅស្រែចំការបង?

ខៈ ស្លូង

កៈ មានស្លូង ដកអីចឹងទៅ?

ខៈ ចាំ!!

កៈ មានច្រូត កាត់អីចឹងហាសណាបង?

ខៈ ចាំ!!ខ្ញុំវាអត់មានស្រែផងនឹង

កៈ ទៅធ្វើអោយគេ?

ខៈ ចាំ!!ខ្ញុំទៅស៊ីឈ្នួលអោយគេនឹង ម៉ែឪរបស់ខ្ញុំលក់អស់ហើយ

កៈ អូ៎!!បាទបង ចុះសំរាប់បងគិតថាដូចជាជីវិតរបស់បង
ដូចជាតាំងពីក្មេងរហូតមកដល់ពេលនេះ បងធ្លាប់ធ្វើអីគេខ្លះដែរទៅ?

ខៈ អើរពីក្មេងនឹងខ្ញុំនឿយមែន តាំងពីការហើយនឹងនិយាយរួមនឹងនឿយតែម្តង
វេទនាទាំងអត់តែម្តងនឹង អត់តាំងពីផ្ទះនៅទៀត

កៈ អូ៎!!បាទ?

ខៈ អានឹងខ្ញុំនិយាយពីប្រវត្តិការតែម្តងហាស

កៈ បាទ!!បងបាទ?

ខៈ ខ្ញុំអត់មានផ្ទះនៅទេទឹកភ្លៀងស្រក់លើខ្លួន
លើក្បាលនឹងអត់មានផ្ទះនៅទេខ្ញុំចេះតែចងស្លឹកចងអី ចងជញ្ជាំងចងអីសំរានទៅណាស់

កៈ បាទ!!បងបាទ?

ខៈ ចាំ!!អានឹងខ្ញុំការហើយ

កៈ ប៉ុន្តែបងធ្លាប់បើកអាជីវកម្មលក់ដូរអីទេ?

ខ៖ ខ្ញុំអត់ផង

ក៖ ចុះលក្ខណៈជាចិញ្ចឹមសត្វហាស ចិញ្ចឹមមាន់ គោ ក្របី ជ្រូក ទាអីបងធ្លាប់ចិញ្ចឹមទេ?

ខ៖ អត់មានផង

ក៖ បងធ្លាប់ចិញ្ចឹមតែឆ្កែណាបង?

ខ៖ អត់មានលុយទិញនឹងគេផងអូនអើយ

ក៖ អ៊ូ!!

ខ៖ មានលុយទៅចេះតែទិញចិញ្ចឹមទៅតែវាអត់មាន

ក៖ ចឹងណាបងណា?

ខ៖ ចាំ!!

ក៖

ចុះបងគិតថាជីវិតរបស់បងមានការផ្លាស់ប្តូរអីគេបងតាំងពីក្មេងរហូតមកដល់ពេលនេះហាសបង?

ខ៖ ផ្លាស់ប្តូរទើបតែឥឡូវនឹងវារៀងស្រួលខ្លួនតិច គ្រាន់តែថាវាអត់ពិបាកដូចមុនហាស

ក៖ បាទ!!បងបាទ?

ខ៖ មុនវាពិបាកណាស់នឿយ

ក៖ ចុះបង?

ខ៖ អត់ទាំងបាយហូបទៀតហោសមុន

ក៖ អ៊ូ!!ចឹងហោសបង ចុះជីវភាព នឹងសុខភាពម៉េចដែរឥឡូវនឹង?

ខ៖ សុខភាពឈឺ

ក៖ ឈឺណាបង?

ខ៖ ចាំ!!ឈឺមួយអាទិត្យជាងហើយនឹង

កៈ អូ៎!!ប៉ុន្តែសុខភាពអីអត់អីទេណបង?

ខៈ ជីវភាពនិយាយរួមវាអត់តែម្តងនឹង វាមិនមែនទាល់ទេ

កៈ អូ៎!!បាទ ចុះបងគិតថាសំរាប់ដូចជាបងចូលចិត្តពិសារម្ហូបអីគេដែរ
តាំងពីក្មេងរហូតមកដល់ពេលនេះ បងនៅតែគិតថាបងនៅតែចូលចិត្តចឹងហាស?

ខៈ ខ្ញុំអត់ភ្លេចទេរឿងស្លសំឡក់ប្រហើរនឹង ម្ជូរនឹង

កៈ អានឹងបងចូលចិត្ត?

ខៈ នឹងហើយនៅខ្មែរយើង

កៈ អូ៎!!

ខៈ ចុះយើងមានអីហូបឆ្ងាញ់ដូចគេ ពីមុនយើងហូបតែចឹងនឹងប្រហុកវ៉ាន់អីវ៉ាន់នឹង
អីចឹងទៅ

កៈ ឥឡូវនឹងនៅតែចូលចិត្តអានឹង?

ខៈ ចាំ!!នៅតែចឹង

កៈ អូ៎!!បាទ ចុះ?

ខៈ អត់មានភ្លេចពីប្រវត្តិមុនទេ

កៈ
បាទ!!បងបាទត្រូវចុះបងគិតថាល្បែងប្រជាប្រិយ៍អីដែរបងចូលចិត្តលេងពីក្មេងហាសបង
ដូចជាចោលឈូង ទាញព្រាត បោះអង្គុញ លាក់កន្សែងអីចឹងហាស?

ខៈ អើរខ្ញុំអត់ដែរលេងសោះ អង្គុញឈូងអីនឹងខ្ញុំអត់ដែរលេងសោះ

កៈ ប៉ុន្តែបងចូលចិត្តរាំទេ?

ខៈ បើថារាំនឹងខ្ញុំទើបតែចូលចិត្តឥឡូវនឹងទេ

កៈ អូ៎!!

ខៈ ក្រមុំខ្ញុំអត់ចេះរាំដែរ ខ្ញុំទើបតែឥឡូវនឹងកូនធំៗនឹងបានខ្ញុំចេះរាំនឹង

កៈ បាទ!!បង?

ខៈ ចាំ!!ខ្ញុំអត់ចេះរលីង

កៈ ចុះបងគិតថាសំរាប់បងចូលចិត្តច្រៀងទេ?

ខៈ អត់ផងអត់ចេះច្រៀងផង

កៈ ប៉ុន្តែបងចូលចិត្តស្តាប់បទចំរៀងទេបងចឹង?

ខៈ ស្តាប់ចេះតែស្តាប់ហើយគ្រាន់តែច្រៀង

កៈ អោយច្រៀងនឹងអត់ចេះច្រៀងទេ?

ខៈ ចាំ!!

កៈ លក្ខណះបែបបទសម័យរឺមួយក៏បទបុរាណដែរបងដែរបងចូលចិត្តស្តាប់ហាសបង?

ខៈ ខ្ញុំចូលចិត្តស្តាប់តែបទបុរាណនឹង

កៈ ចឹងណាបងណា?

ខៈ ចាំ!!

កៈ ភាគច្រើននឹងនរណាគេដែរបង ដូចជាស៊ិនស៊ីសាម៉ុតរឺមួយក៏នរណាគេចឹងហាស?

ខៈ ចាំ!!គាត់នឹងពិរោះ

កៈ អ៎ូ!!បាទបង?

ខៈ ចាំ!!

កៈ ចុះបងគិតថាបងល្ខោនយីកេអាយៃអីនឹងបងចូលចិត្តស្តាប់ទេ?

ខៈ ល្ខោននឹងខ្ញុំលែងមើលសុទ្ធ

កៈ បងអត់ដែរមើល?

ខៈ អត់ចេះមើល

ក៖ អូ៎!!ចុះលក្ខណៈបែបជា
ចុះមាននរណាគេមួយនៅក្នុងក្រុមគ្រួសារបងចេះលេងឧបករណ៍ភ្លេងខ្មែរ រឺមួយក៏អីដែរទេ?

ខ៖ អត់ផងអូន

ក៖ អត់មានចេះទេណាបងណា?

ខ៖ កូនវារករៀនប៉ុន្តែគ្រាន់តែវាចង់រៀនស្អីៗគេប៉ុន្តែយើងវាអត់លុយហាស

ក៖ បាទ!!បងបាទ?

ខ៖ ចង់ទៅរៀនភ្លេងអីនឹងគេប៉ុន្តែវាអត់លុយ អត់មានលុយមានអី

ក៖ អូ៎!!

ខ៖ យើងវាអត់មានលុយ

ក៖ បាទ!!បាទចុះបងគិតថាផ្ទះរបស់បងមានលក្ខណៈបែបណា
តាំងពីក្មេងរហូតមកដល់ពេលនេះហាសបង ដូចថាពីក្មេងនឹងផ្ទះយ៉ាងម៉េច
ហើយឥឡូវនឹងផ្ទះយ៉ាង ម៉េចហាសបង?

ខ៖ ចាំ!!ឥឡូវនឹងផ្ទះវារៀងជិត វាអត់ដូចពីមុន

ក៖ អូ៎!!

ខ៖ ចាំ!!វាដំបូលវាអត់លេចទឹកភ្លៀងហាស

ក៖ បាទ!!បាទបងបាទ?

ខ៖ ចាំ!!ពីមុនទឹកភ្លៀងវាស្រកលើខ្លួន

ក៖ អូ៎!!បាទ?

ខ៖ តែវារៀងទ្រើសជាងមុន មុនកូនដេកវាមិនគ្រាន់ផងនឹងមួយគ្រែនឹង

ក៖ ចុះបងគិតថាផ្ទះណុងនរណាគេជាអ្នកសាងសងដែរបង?

ខ៖ មានប្តី កូន ប្អូន ជាអ្នកធ្វើ

ក៖ ប៉ុន្តែពួកគាត់ចេះធ្វើផ្ទះទាំងអស់គ្នាហោសបង?

ខ៖ ចាំ!!ជួយធ្វើទាំងអស់គ្នា

ក៖ នរណាគេជាអ្នកបង្រៀនអោយពួកគាត់ចេះធ្វើដែរបង?

ខ៖ អើរពុកខ្ញុំគាត់ជាអ្នកនៅប្រឈរជើង

ក៖ អូ៎!!

ខ៖ អោយគាត់ធ្វើមានប្អូនៗៗនឹង

ក៖ បាទ!!

ខ៖ ជួយធ្វើ

ក៖ ចុះបងគិតថាជំនាញអីដែរបងចេះស្ទាត់ជំនាញដែរបង?

ខ៖ ខ្ញុំនឹងហោស?

ក៖ បាទ!!បង

ខ៖ ខ្ញុំអត់មានចេះអីទេអូនអើយនៅតែមើលតែប្អូនហើយនឹងឪនឹង

ក៖ អូ៎!!

ខ៖ បើទៅម្នាក់ទៀតឪអត់មានឪដាំបាយអត់កើតទេ

ក៖ បាទ!!បង?

ខ៖ ចឹងទាល់តែយើងនៅដាំបាយដាំទឹកអោយគាត់ ហើយដល់ពេលដែរប្អូនៗៗវាទៅធ្វើការអស់ចឹងហាស

ក៖ បាទ!!បងបាទ?

ខ៖ ចាំ!!បើយើងទៅទៀតនឹងគាត់មិនដាច់ខ្យល់គាត់ហើយ

ក៖ អូ៎!!ត្រូវហើយបង

ខ៖ ចាំ!!

កៈ ចុះបងគិតថាដូចជាឪពុកម្ដាយរបស់បងគាត់មានធ្លាប់បង្រៀនពីជំនាញអីទៅបងទេ ដូចលក្ខណៈវេញវល្លិ៍ កូរស្ករត្នោត ធ្វើផ្ដៅ ធ្វើកន្ទេលអីចឹងហាស?

ខៈ គាត់អត់មានចេះផង

កៈ អូ៎!!ប៉ុន្តែគាត់មានដែរបង្រៀនទៅបងទេ?

ខៈ អត់ផង

កៈ អត់ផងហោសបង?

ខៈ ចាំ!!

កៈ ចុះបងអាចប្រាប់ពីពេលលំបាកតាំងពីក្មេងរហូតមកដល់ពេលនេះបានទេ ថាបងធ្លាប់ជួបការលំបាកអី គេខ្លះនៅក្នុងជីវិតរបស់បងអីចឹងហាស?

ខៈ លំបាក នឿយណាស់ខ្ញុំ នឿមែនទែនតែម្ដងនឹង

កៈ ចុះកាលពីក្មេងនឹងបងគិតថាបងមានការលំបាកអីផ្សេងទៅបង?

ខៈ លំបាកមកឃ្វាលគោចឹងទៅ រែកទឹកដាំបាយអោយប្អូនស៊ីគួកខោអាវអោយប្អូន

កៈ បាទ!!បង?

ខៈ ស្ទូងគេ ទៅស្ទូងអោយគេចឹងទៅ

កៈ អូ៎!!រហូតទាល់តែមានគ្រួសារបងគិតថាលំបាកអីគេខ្លះដែរទៅបង?

ខៈ គ្រួសារក៏នៅតែលំបាក លំបាកទាល់តែកូនរៀងធំៗៗនឹងបានរៀងស្រួលនឹង

កៈ ពេលនឹងលំបាកអីគេទៅបង ដោយសារតែអត់មានលុយមែនទេ?

ខៈ លំបាកដោយសារតែអត់មានអីធ្វើ ហើយប្ដីរបស់ខ្ញុំនឹងក៏អត់អីធ្វើនៅអត់ធ្វើទាំងអស់គ្នា ហើយនៅដេកហើយប្អូនៗៗនៅតូចហើយនៅចិញ្ចឹមប្អូនៗៗអស់នឹងស្រីៗៗនឹង

កៈ បាទ!!

ខៈ ក៏អត់មានអីហូបដែរហើយខ្ញុំក៏នៅពោះធំពោះអីដែរណាអូន

កៈ បាទ!!បងបាទ?

ខ៖ យើងក៏មានកូនមានអីនៅតូចៗៗវាពិបាកហើយប្តីក៏អត់មានជំនាញអីធ្វើ
គាត់អត់ចេះហាស

ក៖ បាទ!!បងបាទ?

ខ៖ ចាំ!!គាត់អត់ចេះចឹងទៅអត់មានអីទេ
អត់អីហូបទេណាខ្ញុំអង្គុរគេចឹងទៅបបរហូបចឹងទៅអត់មានអីហូប

ក៖ ប៉ុន្តែឥឡូវនឹងធូរហើយណបងណ?

ខ៖ ឥឡូវនឹងវារៀងធូរមួយរយះបន្តិចដែរ

ក៖ មានអីហូបគ្រប់គ្រាន់ហើយឥឡូវនឹងហោស?

ខ៖ ចាំៗ!!គ្រាន់តែថាយើងរក

ក៖  បាទ!!

ខ៖ គាត់ចេះរកពីមុនគាត់អត់ចេះធ្វើអីហាស

ក៖ បាទ!!បងបាទ?

ខ៖ ចាំ!!

ក៖ ចុះបងគិតថាបងឆ្លងកាត់ឧបសគ្គនឹងដោយរបៀបណាដែរបង
ដូចថាជំនះការលំបាកដោយរបៀបណាដែរទៅ?

ខ៖ ខ្ញុំពិបាកហាសពិបាកហាសនិយាយនាំតែពិបាកមែនទែនតែម្តងនឹង

ក៖ អូ៎!!ចុះពេលណាដែរបងគិតថាសប្បាយនៅក្នុងជីវិតរបស់បងវិញចឹងទៅ?

ខ៖ ខ្ញុំរាល់ថ្ងៃខ្ញុំពិបាកពិបាករឿងខ្លួនខ្ញុំឈឺ មិនដឹងឈឺអីទៅអីសំខាន់វាអត់លុយហាស

ក៖ បាទ!!បងបាទ?

ខ៖ ចាំ!!បើខ្ញុំមានលុយខ្ញុំទៅពេទ្យហើយតែខ្ញុំវាអត់លុយ

ក៖ បងដូចជាបងឈឺអីគេទៅបង?

ខ៖ អត់ដឹងថាឈឺអីទេនេះអស់កំលាំងញ័រក្នុងខ្លួននឹងតែម្តងនឹង

កៈ អូ៎!!ប៉ុន្តែឈឺយូរហើយ?

ខៈ ខ្ញុំឈឺយូរហើយឈឺពីរបីអាទិត្យហើយ

កៈ អូ៎!!ប៉ុន្តែយើងអត់អាចធ្វើអីបានទេណបង?

ខៈ វាញ៉រត្រឹតៗៗដៃរនឹងហាស
ប្អូននាំទៅចាក់ថ្នាំដែរប៉ុន្តែវាចាក់តែមួយអន់ថ្នាំនឹងឈឺដដែល

កៈ អូ៎!!បាទបង
ចុះបងគិតថាកាលពីក្មេងបងធ្លាប់មានក្តីស្រម៉ៃថាពេលដែរធំឡើងនឹងបងចង់ធ្វើអីទេ?

ខៈ ចង់ធ្វើអីបើយើងអត់ចេះអក្សរនឹងទៅវាមិនរួច

កៈ អូ៎!!ប៉ុន្តែបងធ្លាប់មានក្តៅស្រម៉ៃថាពេលដែរធំឡើងនឹងបងចង់ធ្វើអីដែរទេ?

ខៈ ចា៎!!ចង់ធ្វើនឹងវាចង់ហើយប៉ុន្តែធ្វើវាមិនកើត

កៈ អូ៎!!ចឹងហោសបង?

ខៈ ចា៎!!បើយើងចេះអក្សរចេះអីចឹងទៅវាកើតហើយណាស់

កៈ បាទ!!បងបាទ?

ខៈ បើយើងអត់ចេះអក្សរចឹងយើងធ្វើអីកើត មានតែស្ទូងដកនឹង

កៈ បាទ!!ង?

ខៈ ហើយនឹងមើលកូនមើលប្អូននឹងមើលក្មួយនឹងមានតែប៉ុណ្ណឹង

កៈ ចុះបងគិតថាបងមានកូនប៉ុន្មាននាក់ដែរ?

ខៈ ខ្ញុំមាន៥នាក់

កៈ មាន៥នាក់ណ
ចុះដូចជាពួកគាត់បានរៀបអាពាហ៍ពិពាហ៍អស់ហើយរឺមួយក៏យ៉ាងម៉េចដែរ?

ខៈ នៅទាំងអស់នឹងអូន

កៈ នៅទាំងអស់ហើយបង?

ខ៖ ចាំ!!

ក៖ ប៉ុន្តែមានប្រុសប៉ុន្មាននឹងស្រីប៉ុន្មានដែរបង?

ខ៖ មានប្រុស៣នាក់នឹង

ក៖ មានប្រុស៣នាក់នឹងស្រីមួយនាក់?

ខ៖ ចាំ!!

ក៖ ចុះពួកគាត់នៅរៀន រឺមួយក៏ពួកគាត់នៅរៀនផងធ្វើការផងបង?

ខ៖ ពួកគាត់នៅរៀន

ក៖ អូ!!បាទបង?

ខ៖ នៅធ្វើការតែអាបងមួយនឹង

ក៖ បាទ!!បងបាទ ចុះបើសិនជាចង់អោយបងផ្តែផ្តាំទៅកូនចៅជំនាន់ក្រោយៗ
បងចង់ផ្តែផ្តាំអីទៅពួកគាត់ដែរបង?

ខ៖ ចាំ!!?

ក៖ បើសិនជាចង់អោយបងផ្តែផ្តាំទៅកូនចៅជំនាន់ក្រោយៗ
តើបងចង់ផ្តែផ្តាំអីទៅពួកគាត់ដែរបង?

ខ៖ ផ្តែផ្តាំជំនាន់ក្រោយនឹងកុំអោយពិបាកវេទនា

ក៖ អូ!!

ខ៖ អោយវាខំរៀនខំអីចឹងទៅ

ក៖ បាទ!!បងបាទ?

ខ៖ នឹងហើយខំរៀនអោយមានចំនេះចេះដឹងទៅ

ក៖
ចុះបើសិនជាចង់អោយពួកគាត់ជៀសវៀងវិញគិតថាបងចង់អោយពួកគាត់ជៀសវៀងអីគេ
ដែរបង?

ខ៖ ជៀសវៀងអារឿងគ្រឿងញៀននឹង

ក៖ អូ៎!!ចឹងណាបងណា?

ខ៖ ចា៎!!

ក៖ អូ៎!!ចឹងមានអីផ្សេងទៀតទេបង?

ខ៖ អត់មានផង

ក៖
បាទ!!ចឹងជាចុងក្រោយខ្ញុំអរគុណច្រើនបងដែរបងបានអោយខ្ញុំបានពិភាក្សាដែរទាក់ទងពីប្រវត្តិរបស់ បងចឹងហាសបងហើយ
ហើយមួយទៀតនឹងខ្ញុំនឹងជូនពរបងអោយឆាបជាពីជំងឺចឹងហាសបង?

ខ៖ ចា៎!!

ក៖ ហើយនឹងរកស៊ីមានបានបង ហើយចឹងអរគុណច្រើនបង៕៕៕